សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance Association

## របាយការណ៍ស្តីពី

# ការឃ្លាំមើលស្ថានភាពសារព័ត៌មាននៅកម្ពុជា ប្រចាំត្រីមាសទី២ ឆ្នាំ២០២៣

ខែមេសា-មិថុនា ឆ្នាំ២០២៣ | លេខចេញផ្សាយ ០៨

របាយការណ៍ប្រចាំត្រីមាសរបស់ខេមបូចា គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងបន្តរបស់យើង ក្នុងការឃ្លាំមើល និងតស៊ូមតិដើម្បីសេរីភាពសារព័ត៌មាននៅកម្ពុជា។ របាយការណ៍នេះរួមបញ្ចូលទាំងព្រឹត្តិការណ៍សង្ខេបខ្លីៗនៃឧប្បត្តិហេតុ និងព័ត៌មានថ្មីៗទាក់ទងនឹងសេរីភាពសារព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិរបស់អ្នកសារព័ត៌មានចាប់ពីខែមេសា ដល់ខែមិថុនា ឆ្នាំ២០២៣។

ក្នុងចំណោមករណីដែលបានកត់ត្រាក្នុងត្រីមាសនេះ គឺមានការបំភិតបំភ័យដោយពាក្យសម្ដីរបស់អ្នកនាំពាក្យក្រសួងមហាផ្ទៃទៅលើអ្នកយកព័ត៌មានខេមបូចាម្នាក់។

ខេមបូចា បានពិនិត្យទៅលើសុវត្ថិភាពរបស់អ្នកសារព័ត៌មានបីទិដ្ឋភាពគឺ ផ្នែករាងកាយ តាមប្រព័ន្ធឌីជីថល និងសុវត្ថិភាពផ្លូវច្បាប់។ ផ្អែកលើប្រភេទទាំងបីនេះ ខេមបូចា បានកត់ត្រាឧប្បត្តិហេតុនៃការយាយីចំនួន៧ករណី មកលើអ្នកសារព័ត៌មានយ៉ាងហោចណាស់៩ នាក់ ក្នុងនោះមានអ្នកសារព័ត៌មានអនឡាញម្នាក់ត្រូវបានចាប់ខ្លួន
រយៈពេលខ្លី។

នៅក្នុងរបាយការណ៍នេះដែរ យើងក៏បានកត់ត្រាព្រឹត្តិការណ៍បច្ចុប្បន្នភាពសំខាន់ៗមួយចំនួនទាក់ទងនឹងបរិយាកាសប្រព័ន្ធផ្សព្វផ្សាយនៅត្រីមាសនេះដែរ។

**ទាំងអស់គ្នាដើម្បីសេរីភាពសារព័ត៌មាន**

# I. ឧប្បត្តិហេតុដែលបានរាយការណ៍នៅក្នុងត្រីមាសនេះ


១ អ្នកធ្វើយុទ្ធនាការព័ត៌មាន ឌីខេមបូឌា ដេលី ទទួលការរងគំរាមសម្លាប់ បន្ទាប់ពីអត្ថាធិប្បាយរិះគន់ខ្លាំងៗទៅលើលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីរដ្ឋាភិបាល........................................................ 6

២ អ្នកថតរូបខេមបូចា រងការឃាយពីសំណាក់អាជ្ញាធរ ពេលកំពុងថតរូបភាពនៃការតវ៉ានៅព្រលានយន្តហោះថ្មី.................................. 8

៣ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន វាយប្រហារអ្នកយកព័ត៌មានវិទ្យុអាស៊ីសេរី...................................................................... 9

៤ អ្នកនាំពាក្យក្រសួងមហាផ្ទៃ ព្រមានអ្នកយកព័ត៌មានខេមបូចា ទាក់ទងនឹងការរាយការណ៍ព័ត៌មានអំពីគណបក្សភ្លើងទៀន.................... 10

៥ អ្នកសារព័ត៌មានអនឡាញម្នាក់ប្រចាំខេត្តកំពង់ធំត្រូវបានឃុំខ្លួនពីបទជំរិតទារប្រាក់.........................................................................12

៦ អតីតអ្នកសារព័ត៌មាន VOD រងការមាក់ងាយពីរដ្ឋមន្ត្រីក្រសួងព័ត៌មានជុំវិញការសរសេរអត្ថបទអំពីកីឡាស៊ីហ្គេមនៅកម្ពុជា.................................13

៧ អ្នកសារព័ត៌មានបីនាក់ត្រូវបង្ខំឲ្យចាកចេញពីសហគមន៍ព្រៃឈើ ពេលចុះយកព័ត៌មានអំពីការកាប់បំផ្លាញព្រៃឈើ....................................14

# II. បច្ចុប្បន្នភាពឧប្បត្តិហេតុសំខាន់ៗ


១ រដ្ឋាភិបាលបញ្ចប់ភាពជាដៃគូវិស័យឯកជនជាមួយហ្វេសប៊ុក បណ្ដេញតំណាងក្រុមហ៊ុនចេញពីកម្ពុជា......15

២ សង្គមស៊ីវិលអំពាវនាវឲ្យបើក វីអូឌី ឡើងវិញ......17

៣ ការព្រួយបារម្ភពាក់ព័ន្ធនឹងសេរីភាពអនឡាញ......18

៤ ចាង់ហ្វាង់កាសែតជាយដែន ត្រូវបានដោះលែងឱ្យនៅក្រៅឃុំ បន្ទាប់ពីត្រូវជាប់ឃុំបណ្ដោះអាសន្នរយៈពេលបីខែ......20

៥ សន្ទស្សន៍សេរីភាពសារព័ត៌មានឆ្នាំ២០២៣ របស់កម្ពុជាបន្តធ្លាក់ចុះ......20

# សេចក្តីសង្ខេប នៃឧប្បត្តិហេតុនៃការយាយីលើអ្នកសារព័ត៌មាន ដែលកត់ត្រាចាប់ពីថ្ងៃទី ១ ខែមេសា ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២៣

| ទិដ្ឋភាពសុវត្ថិភាព | ប្រភេទនៃការយាយី | ចំនួននៃអង្គភាពសារព័ត៌មាន/ អ្នកកាសែតដែលរងការប៉ះពាល់ |
|---|---|---|
| *សុវត្ថិភាពផ្លូវកាយ* | *ការវាយប្រហារលើឧបករណ៍និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនការបំពានលើរាងកាយ ការគំរាមកំហែងដោយពាក្យសំដី* | *អ្នកសារព័ត៌មានប្រាំមួយនាក់រងការយាយី និងគំរាមកំហែង។ ក្នុងនោះអ្នកយកព័ត៌មានអនឡាញម្នាក់ត្រូវបានចាប់ឃុំខ្លួន* |
| *សុវត្ថិភាពអនឡាញ* | *ការបៀតបៀនផ្លូវភេទតាមអនឡាញ ការសម្លុតតាមអនឡាញ* | *អតីតអ្នកយកព័ត៌មាន VOD ម្នាក់ និងអ្នកសារព័ត៌មានបរទេសស្ត្រីម្នាក់ និងអ្នកយកព័ត៌មានវិទ្យុអាស៊ីសេរីខ្មែរម្នាក់* |
| *សុវត្ថិភាពផ្លូវច្បាប់* | *ការបិទ ឬផ្អាកប្រព័ន្ធផ្សព្វផ្សាយពីសំណាក់អាជ្ញាធរ* | |

# I. ឧប្បត្តិហេតុដែលបានរាយការណ៍នៅក្នុងត្រីមាសនេះ

## ១. អ្នកឆ្លើយឆ្លងព័ត៌មាន ឌឺខេមបូឌា ដេលី រងការគំរាមសម្លាប់ បន្ទាប់ពីរិះគន់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន

*កាលពីថ្ងៃទី១៩ ខែមិថុនា លោក តាំង សារ៉ាដា ប្រធានផ្នែកប្រព័ន្ធផ្សព្វផ្សាយជាភាសាខ្មែរ ឌឺ ខេមបូឌា ដេលី ប្រចាំទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក បានអះអាងថា លោកបានទទួលការគំរាមសម្លាប់ពីលោក ផែង វណ្ណៈ ដែលជាអ្នកលេងបណ្តាញសង្គមគាំទ្ររដ្ឋាភិបាល បន្ទាប់ពីលោកសារ៉ាដា រិះគន់ខ្លាំងៗទៅលើលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងក្រុមគ្រួសារ ក្នុងកម្មវិធី Idea Talk របស់ខ្លួន ។*

*លោកសារ៉ាដា បានបង្ហោះចែករំលែកសារសំឡេងលោក វណ្ណៈថា គាត់នឹងពុះក្បាលលោកសារ៉ាដានឹងពូថៅ ប្រសិនបើលោកសារ៉ាដាចូលស្រុកខ្មែរ។ លោកសារ៉ាដាដែលរស់នៅក្រៅប្រទេសក៏បានចោទប្រកាន់លោក វណ្ណៈ ថាបានគំរាមកំហែងគ្រួសារលោក រួមទាំងឪពុកម្តាយរបស់លោកដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាហើយ*

លោកបញ្ជាក់ថា ភ្នាក់ងារគណបក្សប្រជាជនកម្ពុជានៅសហរដ្ឋអាមេរិកអាចនឹងធ្វើបាបរូបលោកបាន។

លោកសារ៉ាដា បាននិយាយថា "បន្ទាប់ពីខ្ញុំបានទទួលការគំរាមកំហែងទាំងនេះ កាលពីថ្ងៃពុធនៅម៉ោងប្រហែល១ រសៀល មានមនុស្សចម្លែកម្នាក់បានមកគោះទ្វារផ្ទះរបស់ខ្ញុំខ្លាំងៗ ប៉ុន្តែខ្ញុំមិនហ៊ានបើកទេ"។

លោកបាននិយាយថា ៖ «ឪពុកម្ដាយក្មេករបស់ខ្ញុំ និងកូនប្រុសអាយុប្រាំបីឆ្នាំរបស់ខ្ញុំភ័យខ្លាចខ្លាំងណាស់។

នៅម៉ោង៤រសៀលថ្ងៃដដែល ខ្ញុំបានឃើញរថយន្តពណ៌ខ្មៅចម្លែកមួយដែលមើលទៅដូចជារថយន្តស៊ើបការណ៍ បានឈប់ ហើយចតនៅមុខផ្ទះខ្ញុំ ហើយមានមនុស្សអង្គុយនៅក្នុងរថយន្តអស់ជាច្រើនម៉ោង»។

កាលពីថ្ងៃទី ២២ មិថុនា នៅក្នុងការផ្សាយផ្ទាល់តាមហ្វេសប៊ុកមួយទៀត លោក ផែង វណ្ណៈ បាននិយាយថា លោកនឹងមិនស្ទាក់ស្ទើរក្នុងការបំផ្លាញអ្នកណាដែលបំផ្លាញសន្តិភាព និងស្ថិរភាពនៅកម្ពុជានោះទេ។

ប្រភព៖ https://tinyurl.com/5n6s9ec9

https://tinyurl.com/4vp757m2

## ប្រភេទនៃការយាយី៖ ការបំភិតបំភ័យតាមអនឡាញ

# ២. អ្នកថតរូបខេមបូចា រងការយាយីពីសំណាក់អាជ្ញាធរ ពេលកំពុងថតរូបការតវ៉ានៅតំបន់ព្រលានយន្តហោះថ្មី។

*កាលពីថ្ងៃទី ៨ ខែមិថុនា ប្រធានអ្នករូបថតខេមបូចា លោក ព្រីង សំរាំង ត្រូវបានអាជ្ញាធរសាកសួរ ហើយថតកាតកាសែតរបស់គាត់ ខណៈគាត់កំពុងថតអ្នកភូមិតវ៉ារឿងចាក់ដីលុបក្បែរផ្ទះរបស់ពួកគេក្នុងគម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះដែលមានតម្លៃ ១.៥ ពាន់លានដុល្លារក្នុងខេត្តកណ្ដាល។*

*អ្នកភូមិប្រហែល ៣០នាក់មកពីឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង មានចម្ងាយប្រហែល ៥គីឡូម៉ែត្រពីការដ្ឋានអភិវឌ្ឍន៍ព្រលានយន្តហោះ បាននាំគ្នាតវ៉ាប្រឆាំងនឹងការចាក់ដីលុបក្បែរផ្ទះរបស់ពួកគេ។*

*មន្ត្រីអាជ្ញាធរមូលដ្ឋាន និងនគរបាលរាប់សិបនាក់ បានដាក់ពង្រាយនៅកន្លែងតវ៉ា។*

*លោក សំរាំង បាននិយាយថា ខណៈពេលដែលលោកកំពុងថតរូបអ្នកភូមិតវ៉ានោះ មានបុរសម្នាក់ស្លៀកពាក់ស៊ីវិលបានដើរតម្រង់មករកលោក ហើយបានថតរូបលោក និងកាតកាសែតរបស់លោក។ ភ្លាមនោះបុរសនោះក៏បានចាកចេញទៅ ប៉ុន្តែក្រោយមកបានត្រឡប់មកវិញ ហើយបានឲ្យលោកសំរាំងទៅជួបថ្នាក់លើរបស់ខ្លួន។ លោក សំរាំងបានបដិសេធ ហើយបានចាកចេញពីទីនោះភ្លាមៗដែរ បន្ទាប់ពីអ្នកភូមិប្រាប់លោកឲ្យចាកចេញ ដើម្បីជៀសវាងការចាប់ខ្លួន។*

*ប្រភព៖ ការសម្ភាសក្នុងអង្គភាពសារព័ត៌មានដោយខេមបូចា*

**ប្រភេទនៃការយាយី៖ ការបំភិតបំភ័យផ្លូវកាយ**

## ៣. លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន វាយប្រហារអ្នកយកព័ត៌មានវិទ្យុអាស៊ីសេរី

*នៅថ្ងៃទី៤ ខែមិថុនា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានរិះគន់វិទ្យុអាស៊ីសេរី ភាសារខ្មែរដោយហៅអ្នកយកព័ត៌មានម្នាក់ថាជាមនុស្សភ្លើ។ លោក ហ៊ុន សែន ព្រមានថា បើវិទ្យុអាស៊ីសេរីខ្មែរ ចង់បើកការិយាល័យនៅភ្នំពេញឡើងវិញ ចាំបាច់ត្រូវដកអ្នកយកព័ត៌មានដែលលោកហៅថាមនុស្សភ្លើចេញ។*

*ទោះបីជាលោកនាយករដ្ឋមន្ត្រីមិនបាននិយាយចំឈ្មោះអ្នកយកព័ត៌មានរូបនោះក៏ដោយ ក៏លោកទំនងជាសំដៅទៅលើលោក ជុន ច័ន្ទបុត្រ អ្នកគ្រប់គ្រងវិទ្យុអាស៊ីសេរីខ្មែរដែរ។*

*កាលពីឆ្នាំ២០១៧ វិទ្យុអាស៊ីសេរីខ្មែរបានបិទការិយាល័យរបស់ខ្លួននៅភ្នំពេញ បន្ទាប់ពីបុគ្គលិករបស់ខ្លួនពីរនាក់ត្រូវបានចាប់ខ្លួនពីបទចារកម្ម។ នៅពេលនោះ វិទ្យុអាស៊ីសេរីបានលើកឡើងថា «មិនអាចបន្តប្រតិបត្តិករនៅកម្ពុជាបានទេ។*

*ប្រភព៖* https://tinyurl.com/2sdjmpkz

**ប្រភេទនៃការយាយី៖**
**ការសម្លុតតាមអនឡាញ**

## ៤. អ្នកនាំពាក្យក្រសួងមហាផ្ទៃ ព្រមានអ្នកយកព័ត៌មានខេមបូចា ទាក់ទងនឹងការរាយការណ៍ព័ត៌មានពីគណបក្សភ្លើងទៀន។

*អ្នកយកព័ត៌មានខេមបូចា លោក ឃួន ណារីម បានរងការគំរាមដោយពាក្យសំដីពីអ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័គ ក្នុងបទសម្ភាសន៍តាមទូរស័ព្ទកាលពីថ្ងៃទី ២៩ ឧសភា។ លោក សុភ័គ បានព្រមានអ្នកយកព័ត៌មានថា លោកអាចជាប់គុក ដោយសារសួរសំណួរអំពីគណបក្សភ្លើងទៀន។*

*លោក សុភ័គ និយាយថា «សួរ ឆ្កួតៗអ៊ីចឹង អ្នកកាសែតចង់ចូលគុក?។*

*នេះមិនមែនជាលើកទីមួយទេដែលអ្នកសារព័ត៌មានខេមបូចារងការព្រមានឬការគំរាមពីមន្ត្រីក្រសួងមហាផ្ទៃរូបនេះ។ ក្នុងខែឧសភាដដែល លោក ណារីម រងការព្រមានបីដងពីលោក សុភ័គ ខណៈធ្វើសេចក្តីរាយការណ៍ព័ត៌មានអំពីបក្សគណបក្សភ្លើងទៀន។*

*កាលពីថ្ងៃទី១២ ឧសភា លោក ណារីម បានហៅទូរស័ព្ទទៅលោក សុភ័គ ដោយសួរថា ហេតុអ្វីបានជាក្រសួងមហាផ្ទៃមិនផ្តល់លិខិតច្បាប់ដើមថតចម្លងស្តីពីការចុះបញ្ជីគណបក្សភ្លើងទៀនជាមួយក្រសួងមហាផ្ទៃ ប៉ុន្តែបែរជាចេញតែលិខិតបញ្ជាក់ទៅវិញ។*

*លោកសុភ័គក៏ឆ្លើយថា"តើលោកឯងនៅជាមួយបក្សភ្លើងទៀន? តើខេមបូចាកាន់ជើងគណបក្សភ្លើងទៀន? លោកឯងត្រូវសួរក្នុងនាមអ្នកកាសែត គឺមិនមែនក្នុងនាមជាអ្នកនាំពាក្យរបស់បក្សភ្លើងទៀនទេ"។*

*លោកបន្តថា «សូមធ្វើជាអ្នកកាសែតអាជីព ហើយកុំធ្វើជាអ្នកកាសែតស៊ីឈ្នួលបម្រើបរទេស។*

*តើនរណាឲ្យលុយខេមបូចា?។*

*កាលពីថ្ងៃទី៩ ខែឧសភា បន្ទាប់ពីមានកិច្ចប្រជុំរវាងក្រសួងមហាផ្ទៃ និងថ្នាក់ដឹកនាំគណបក្សភ្លើងទៀន លោក ណារីម ហៅទូរស័ព្ទទៅលោក សុភ័គ ដើម្បីសាកសួរអំពីលទ្ធផលនៃកិច្ចប្រជុំនោះ...។*

*ទោះជាយ៉ាងនេះក្តី លោក សុភ័គ បែរជាចោទសួរលោក ណារីម អំពីប្រភពមូលនិធិ ដែលខេមបូចាទទួលបានទៅវិញ។*

*លោក សុភ័គ បាននិយាយថា "តើលោកឯងបានប្រាក់ខែពីអ្នកណា? លោកឯងត្រូវតែដឹងពីប្រភពមូលនិធិ។*

*ខ្ញុំចង់សួរថា តើអ្នកណាគាំទ្រខេមបូចា? តើខេមបូចា ទទួលបានមូលនិធិពីណា ដើម្បីធ្វើការងារនោះ?"។*

*លោក សុភ័គ បានបន្តថា "ខ្ញុំនឹងមិនផ្តល់ព័ត៌មានទេ បើសូម្បីតែលោកឯងក៏មិនដឹងថាលោកឯងជាអ្នកណាផងនោះ។ ខ្ញុំក៏មិនដឹងថា ខេមបូចា មកពីណាដែរ អ៊ីចឹងតើឲ្យខ្ញុំផ្តល់ព័ត៌មានដល់លោកឯងយ៉ាងម៉េចទៅ? ក្នុងនាមជាអ្នកកាសែត លោកឯងត្រូវតែបង្ហាញអត្តសញ្ញាណខ្លួនឯង"។*

*ប្រភព៖ ការសម្ភាសក្នុងអង្គភាពដោយខេមបូចា*

**ប្រភេទនៃការយាយី៖**
**ការគំរាមកំហែងដោយពាក្យសំដី**

## ៥. អ្នកសារព័ត៌មានអនឡាញប្រចាំខេត្តកំពង់ធំត្រូវបានឃុំខ្លួនពីបទជំរិតទារប្រាក់

*លោក សឿន សុជា អ្នកយកព័ត៌មានអនឡាញរបស់TNM ត្រូវបានកងរាជអាវុធហត្ថខេត្តកំពង់ធំចាប់ខ្លួនកាលពីថ្ងៃទី១០ ខែឧសភា ហើយយកទៅឃុំខ្លួនពីបទជំរិតទារប្រាក់។*

*លោក សែម បូរ៉ា ដែលជាចាងហ្វាង TNM បានប្រាប់ខេមបូចាថា សុជាទើបតែចាប់ផ្តើមធ្វើការឱ្យសារព័ត៌មាននេះនៅឆ្នាំ២០២១ ចំណែកឯការចោទប្រកាន់នេះកើតឡើងនៅឆ្នាំ២០២០ទៅវិញ។ លោក បូរ៉ា បាននិយាយថា ការចោទប្រកាន់មកលើលោក សុជា គឺផ្តើមចេញពីការរាយការណ៍ព័ត៌មានជាបន្តបន្ទាប់អំពីការកាប់ឈើខុសច្បាប់នៅក្នុងខេត្តកំពង់ធំ។*

*លោក បូរ៉ា បានទទួលស្គាល់ថា លោក សុជា បានទទួលប្រាក់ ១០ ដុល្លារពីឈ្មោះ ហេង នី ជាឈ្មួញរកស៊ីឈើ ប៉ុន្តែលោកថា នេះមិនគួរចាត់ទុកថាជាការជំរិតនោះទេ។ លោក បូរ៉ា បាននិយាយថា៖ «ហេង នី ឲ្យលុយសុជាខ្វះ ប៉ុន្តែ លោកសុជា មិនបានជំរិតទេ។ តាមខ្ញុំដឹង គាត់ទទួលបានប្រហែល ១០ ដុល្លារម្តងៗ»។*

*លោក បូរ៉ា បានបន្ថែមថា អាជ្ញាធរខេត្តកំពង់ធំ បានព្រមានលោក សុជា និងអង្គភាពសារព័ត៌មានលោកជាច្រើនលើកច្រើនសារ មិនឲ្យរាយការណ៍ព័ត៌មានអំពីការកាប់ឈើខុសច្បាប់ និងបញ្ហាបរិស្ថានទេ។*

*នៅថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២៣ ចាងហ្វាងរបស់TNM បានសរសេរលិខិតមួយច្បាប់ទៅកាន់រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដើម្បីស្វែងរកការអន្តរាគមន៍។ លិខិតនោះបានបញ្ជាក់ថា ឈ្មួញរកស៊ីឈើបីនាក់ និងមន្ត្រីបរិស្ថានម្នាក់បានប្តឹងលោក សុជា ពីបទផ្សាយព័ត៌មានមិនពិត ញុះញង់ និងជំរិតទារប្រាក់ដែលបានប្រព្រឹត្តក្នុងឆ្នាំ២០២០ បើទោះបីជាលោក សុជា មិនទាន់ចាប់ផ្តើមធ្វើការជាអ្នកយកព័ត៌មានឲ្យTNM នៅពេលនោះក៏ដោយ។*

*លិខិតនោះបញ្ជាក់ថា «នេះជាទង្វើបំភិតបំភ័យអ្នកសារព័ត៌មានដែលហ៊ានរាយការណ៍ការពិតក្នុងខេត្តកំពង់ធំ ព្រោះវាប៉ះពាល់ដល់ផលប្រយោជន៍របស់មន្ត្រីបរិស្ថាន និងឈ្មួញរកស៊ីឈើដែលទទួលបានផលប្រយោជន៍ពីការកាប់ឈើខុសច្បាប់»។*

*លោក សុជា ត្រូវបានដោះលែងឲ្យនៅក្រៅឃុំកាលពីថ្ងៃទី១ ខែមិថុនា បន្ទាប់ពីលោកបានសុំទោស និងទទួលស្គាល់ថា ការរាយការណ៍ព័ត៌មានរបស់ខ្លួនមិនមានការផ្ទៀងផ្ទាត់ច្បាស់លាស់។*

*ប្រភព៖ ខេមបូចា បានសម្ភាសចាងហ្វាង TNM និងមេធាវីរបស់លោក សុជា*

https://tinyurl.com/2p93pn7f

**ប្រភេទនៃការយាយី៖**
**ការបំភិតបំភ័យផ្លូវកាយ**

## ៦. អតីតអ្នកសារព័ត៌មាន VOD រងការយាយីពីរដ្ឋមន្ត្រីក្រសួងព័ត៌មាន ទាក់ទងការរាយការណ៍ព័ត៌មានកីឡាស៊ីហ្គេម

*រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ បានប្រតិកម្មតបទៅនឹងការរាយការណ៍ព័ត៌មានរបស់កាសែត* Nikkei Asia *ស្តីពីការរៀបចំកីឡាស៊ីហ្គេមនៅកម្ពុជា ដោយអះអាងថា វាមិនមែនជាការពិតដូចសេចក្តីរាយការណ៍នោះទេ។*

*អត្ថបទព័ត៌មានដែលមានចំណងជើងថា "ស៊ីហ្គេមនៅកម្ពុជា៖ កម្មករ និងអត្តពលិក ហៅការកសាងកីឡដ្ឋានមានភាពរញ៉េរញ៉ៃ" បានផ្សាយកាលពីថ្ងៃទី ៤ ឧសភា។ វាបានពិពណ៌នាអំពីបញ្ហាប្រឈមដែលកម្ពុជាកំពុងធ្វើជាម្ចាស់ផ្ទះស៊ីហ្គេមរួមមានការកកស្ទះចរាចរណ៍ ជីវភាពក្រីក្រតោកយ៉ាករបស់កម្មករ និង កង្វះការរៀបចំសម្រាប់ព្រឹត្តិការណ៍មួយចំនួន។*

*នៅក្នុងការបង្ហោះតាម* Facebook *កាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៣ លោក កាញារីទ្ធ បានហៅការរាយកាណ៍ព័ត៌មាននេះថា «បន្ទាបបន្ថោក» ហើយបានចោទប្រកាន់អ្នកសរសេរអត្ថបទ គឺលោក ម៉ិច ដារ៉ា អតីតអ្នកយព័ត៌មាន វីអូឌី ដែលរដ្ឋាភិបាលបានបិទកាលពីខែកុម្ភៈ ថាជាអ្នកកាសែត«ថោក» ដែលបម្រើផលប្រយោជន៍បរទេស។*

*លោក កាញារីទ្ធ បានសរសេរថា "យើងទទួលស្គាល់ថា កម្ពុជាមិនទាន់ក្លាយជាស្ថានសួគ៌ទេ តែការប្រឹងប្រែងរបស់ប្រទេសកម្ពុជាទាំងមូល ទទួលបានត្រឹមតែរូបថត ៣ សន្លឹក និង អត្ថបទបន្ទាបបន្ថោកគ្រប់បែបយ៉ាងពីលោក ម៉ិច ដារ៉ា និង បក្សពួក នៅលើទំព័រកាសែតអន្តរជាតិមួយទៅវិញ" ។*

*ស៊ីហ្គេមជាព្រឹត្តិការណ៍កីឡាដ៏សំខាន់មួយដែលប្រារព្ធឡើងរៀងរាល់ពីរឆ្នាំម្តងក្នុងតំបន់អាស៊ីអាគ្នេយ៍។ស៊ីហ្គេមឆ្នាំ២០២៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១៦ ខែឧសភា។*

*ប្រភព៖* *(ការថតតាមហ្វេសប៊ុករបស់រដ្ឋមន្ត្រី)*

https://tinyurl.com/4z3v2nar

https://tinyurl.com/56pshrv9

**ប្រភេទនៃការយាយី៖**
**ការសម្លុតតាមអនឡាញ**

## ៧. អ្នកកាសែតបីនាក់ត្រូវបង្ខំឲ្យចាកចេញពីសហគមន៍ព្រៃឈើ ខណៈរាយការណ៍ព័ត៌មានអំពីការកាប់បំផ្លាញព្រៃឈើ

*កាលពីថ្ងៃទី ២១ ខែមេសា អ្នកយកព័ត៌មានបរទេសម្នាក់ លោក* Gerry Flynn *មកពីអង្គភាពសារព័ត៌មានម៉ុងហ្គាបៃ និងអ្នកកាសែតសេរីពីរូបគឺ* Andy Ball *សញ្ជាតិអង់គ្លេស និងលោក ម៉េង គ្រីពន្ធក ជាជនជាតិខ្មែរ ត្រូវបានមន្ត្រីឧទ្យានុរក្សក្រសួងបរិស្ថានបង្ខំឱ្យចាកចេញពីសហគមន៍ព្រៃឈើព្រះរកាក្នុងខេត្តព្រះវិហារខណៈកំពុងរាយការណ៍ព័ត៌មានអំពីការកាប់បំផ្លាញព្រៃឈើ។*

*អ្នកកាសែតទាំងបីនាក់ត្រូវបានគេបណ្ដើរចេញពីព្រៃ និងដោះលែងដោយមិនមានការឃុំខ្លួនទេ។ លោក* Flynn *បាននិយាយថា "គេប្រាប់យើងថាមិនឲ្យយើងនៅក្នុងព្រៃទេ ព្រោះយើងមិនបានសុំការអនុញ្ញាតពីអាជ្ញាធរ" ។*

*លោក* Flynn *បានទៅថតវីដេអូ ពីការដើរល្បាតព្រៃរបស់សហគមន៍ដែលជាផ្នែកនៃវីដេអូ តាមដានការបំផ្លាញព្រៃឈើ របស់អង្គភាពសារព័ត៌មាន* Mongabay *។ លោកជ្រើសរើសសហគមន៍ព្រះរកា ព្រោះវាជាព្រៃដែលមានសុវត្ថិភាពជាងកន្លែងដទៃ ដើម្បីចុះល្បាត ដោយកាត់តាមដែនជម្រកសត្វព្រៃព្រៃឡង់ ដែលនៅក្បែរគ្នានោះ។*

*លោក* Flynn *បាននិយាយថា លោកបានជូនដំណឹងដល់អង្គការសិទ្ធិមនុស្សលីកាដូ អំពីបេសកកម្មរបស់លោកជាមុន។ លោកប្រាប់ ខេមបូចា ថា អង្គការលីកាដូបាននិយាយជាមួយបណ្ដាញអង្គការសង្គមស៊ីវិល។ ការណ៍នេះនាំឱ្យការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស* (OHCHR) *ប្រចាំកម្ពុជានិយាយដោយផ្ទាល់ជាមួយរដ្ឋបាលខេត្តព្រះវិហារ។ រដ្ឋបាលខេត្តបានយល់ព្រមមិនឃុំខ្លួនអ្នកកាសែតទាំងបីនាក់នោះទេ។*

*លោក* Flynn *បាននិយាយថា៖ «ប្រសិនបើយើងមិនបានជូនដំណឹងដល់អង្គការក្រៅរដ្ឋាភិបាលទេ យើងប្រហែលជាត្រូវប្រឈមមុខនឹងនគរបាល ឬតុលាការហើយ»។*

*ប្រភព៖ ខេមបូចា សម្ភាស លោក* Gerry Flynn

**ប្រភេទនៃការយាយី៖**
**ការបំភិតបំភ័យផ្លូវកាយ**

# II. ព្រឹត្តិការណ៍បច្ចុប្បន្នភាពសំខាន់ៗអំពីស្ថានភាពអង្គភាពសារព័ត៌មាននៅកម្ពុជា

## ១. រដ្ឋាភិបាលបញ្ចប់ភាពជាដៃគូក្នុងវិស័យឯកជនជាមួយហ្វេសប៊ុក បណ្តេញតំណាងក្រុមហ៊ុនចេញពីប្រទេស

*បន្ទាប់ពីគណនីហ្វេសប៊ុករបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវផ្អាក រដ្ឋាភិបាលក៏បានប្រកាសកាលពីថ្ងៃសៅរ៍ថា តំណាងរបស់ហ្វេសប៊ុក ក៏នឹងត្រូវបណ្តេញចេញពីប្រទេសដែរ។*

*ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបញ្ជាក់នៅក្នុងលិខិតមួយ ដែលបង្ហោះលើទំព័រហ្វេសប៊ុក របស់ខ្លួនថា គេហទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមនឹងតម្រូវឱ្យ «បញ្ឈប់រាល់សកម្មភាព ដូចជា ភាពជាតំណាងរបស់ក្រុមហ៊ុន ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងកិច្ចសហការដៃគូក្នុងវិស័យឯកជននៅកម្ពុជា។*

*ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍លើកឡើងពីភាពមិនប្រក្រតីនៃសេវារបស់ក្រុមហ៊ុនហ្វេសប៊ុក*(Facebook) *សម្រាប់អ្នកប្រើប្រាស់នៅកម្ពុជា ដូចជា ការបង្កើតគណនីក្លែងក្លាយ ហានិភ័យលើទិន្នន័យឯកជន ការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ និងការជ្រៀតជ្រែកចូលកិច្ចការនយោបាយរបស់ប្រទេស។*

*លោក ហ៊ុន សែន ធ្លាប់បានព្រមានថា លោកអាចនឹងបិទប្រតិបត្តិការរបស់បណ្តាញហ្វេសប៊ុកទាំងស្រុងក្នុងប្រទេសកម្ពុជា ប៉ុន្តែក្រោយមក លោកក៏បែរជាលុបគណនីផ្ទាល់ខ្លួនរបស់លោកដែលមានអ្នកតាមដានជាង ១៤ លាននាក់ដោយខ្លួនឯង។*

*លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍នៅក្នុងខ្សែវីដេអូមួយដែលបានផ្សព្វផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយដែលគាំទ្ររដ្ឋាភិបាលកាលពីថ្ងៃសុក្រថា "ខ្ញុំមិនល្ងង់រហូតទៅដល់បិទហ្វេសប៊ុក ដែលប្រជាជនមានតម្រូវការទំនាក់ទំនង ហើយទទួលយកនូវព័ត៌មាននេះ" ។*

*លោក ហ៊ុន សែន ថាលោកបានប្តូរមកប្រើ តេឡេក្រាម វិញ ព្រោះមានគណនីហ្វេសប៊ុក ក្លែងក្លាយច្រើនពេក ហើយលោកបារម្ភពីពួកលួចទិន្នន័យ។*

*លោកបាននិយាយថា៖ «ដូច្នេះគ្មានហេតុអ្វីដែលខ្ញុំមានការចាំបាច់ ដើម្បីប្រើហ្វេសប៊ុកនោះទេ»។*

*ក្រុមប្រឹក្សាត្រួតពិនិត្យរបស់ក្រុមហ៊ុនមេតាដែលគ្រប់គ្រងហ្វេសប៊ុកបានស្នើឲ្យព្យួរគណនីរបស់លោកហ៊ុនសែន រយៈពេល ៦ ខែ។*

ប៉ុន្តែកម្រិតនៃការសម្រេចរបស់រដ្ឋាភិបាលក្នុងការកាត់ផ្តាច់ទំនាក់ទំនងសាធារណៈនិងឯកជនជាមួយបណ្តាញហ្វេសប៊ុក នឹងត្រូវបានអនុវត្តយ៉ាងដូចម្តេច ហើយមានផលប៉ះពាល់យ៉ាងណាមកលើប្រជាជនកម្ពុជា ដែលពឹងផ្អែកលើបណ្តាញហ្វេសប៊ុក ដើម្បីប្រើប្រាស់អ៊ីនធឺណិត និងតម្រូវការផ្នែកសេដ្ឋកិច្ច គឺនៅមិនទាន់ច្បាស់នៅឡើយ។

យោងតាមអ្នកប្រមូលទិន្នន័យនៃបណ្តាញទិន្ន័យ Data Reportal ក្នុងឆ្នាំ២០២២ ប្រជាជនកម្ពុជាប្រើប្រាស់ហ្វេសប៊ុក ច្រើនជាង១១ លាននាក់ ក្នុងចំណោមប្រជាពលរដ្ឋ១៦.៩ លាននាក់ ។

ក្រុមហ៊ុនទូរគមនាគមន៍ឈានមុខគេជាច្រើនផ្តល់ជូន នូវការផ្សព្វផ្សាយពាណិជ្ជកម្មតាមរយៈហ្វេសប៊ុក ក្រុមហ៊ុនទូរស័ព្ទចល័តធំទីពីររបស់កម្ពុជាស្មាត(Smart)ផ្សាយទិន្នន័យគ្មានដែនកំណត់នៅលើគេហទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមក្នុងតម្លៃ ២ ដុល្លារក្នុងមួយថ្ងៃ។ អ្នកប្រើប្រាស់ស្មាតមួយចំនួនត្រូវបានគេបង្កើតប្រវត្តិរូបហ្វេសប៊ុកដោយស្វ័យប្រវត្តិ នៅពេលពួកគេចុះឈ្មោះជាមួយក្រុមហ៊ុន។

អតីតនាយកប្រតិបត្តិក្រុមហ៊ុន ស្មាត អាស្យាតា (Smart Axiata) លោក Thomas Hundt បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយដែលមិនមានចុះកាលបរិច្ឆេទនៅលើគេហទំព័ររបស់ក្រុមហ៊ុនថា"ដោយដឹងថាការក្លាយជាផ្នែកមួយនៃសហគមន៍ហ្វេសប៊ុក គឺជាកត្តាជំរុញដ៏សំខាន់មួយសម្រាប់ការប្រើប្រាស់អ៊ិនធឺណិតចល័ត ដូច្នេះវាជាគោលបំណងរបស់យើង ដើម្បីធ្វើឱ្យវាមានភាពងាយស្រួលតាមដែលអាចធ្វើទៅបាន និងមានតម្លៃសមរម្យតាមដែលអាចធ្វើទៅបានក្នុងការប្រើប្រាស់ហ្វេសប៊ុក" ។

ក្រុមហ៊ុនស្មាត មិនបានឆ្លើយតបទៅនឹងសំណើសុំការអត្ថាធិប្បាយអំពីថាតើការផ្សព្វផ្សាយបែបនេះនឹងប៉ះពាល់ដល់សេចក្តីថ្លែងការណ៍របស់ក្រសួងនោះទេ។

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លោក ជា វ៉ាន់ដេត បដិសេធមិនធ្វើអត្ថាធិប្បាយទេ ហើយបានបង្វែរសំណួរទៅរដ្ឋលេខាធិការ លោក សូ វិសុទ្ធ ដែលមិនអាចទាក់ទងបានទេ។

អ្នកនាំពាក្យក្រុមហ៊ុនមេតា បានប្រាប់ខេមបូចា ថា "យើងមិនមានយោបល់អ្វីទេនៅពេលនេះ" ។

ប្រភព៖ https://tinyurl.com/2648zhyc

# ២. សង្គមស៊ីវិលអំពាវនាវឲ្យបើក វីអូឌី ឡើងវិញ

*នៅមុនទិវាសេរីភាពសារព័ត៌មានពិភពលោកក្រុមសង្គមស៊ីវិលបានអំពាវនាវឲ្យរដ្ឋាភិបាលអនុញ្ញាតឲ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ VOD បើកឡើងវិញ ដោយកត់សម្គាល់ថា សេរីភាពសារព័ត៌មានរបស់ប្រទេស គឺបន្តធ្លាក់ចុះ។*

*នាយកប្រតិបត្តិមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោកស្រី ចក់ សុភាព បានថ្លែងក្នុងកិច្ចពិភាក្សាអំពីសេរីភាពសារព័ត៌មានក្នុងទីក្រុងភ្នំពេញកាលពីថ្ងៃទី ២ ឧសភា គឺមួយថ្ងៃមុនទិវាសេរីភាពសារព័ត៌មានពិភពលោកថា "ខ្ញុំសង្ឃឹមថាលោកនាយករដ្ឋមន្ត្រីនឹងពិចារណាដោយការសណ្ដោសទៅលើ [ការឲ្យបើក VOD ឡើងវិញ]"។*

*លោកស្រីនិយាយថា៖ «យើងអាចនិយាយបានថា វាជាកំហុសមួយដែល VOD បានប្រព្រឹត្តខុស ប៉ុន្តែ VOD បានសុំទោសរួចហើយ»។*

*កាលពីខែកុម្ភៈ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានទុកពេលឲ្យVOD ៧២ម៉ោង ក្រោយមកក៏កំណត់មកត្រឹម ២៤ ម៉ោងវិញ ដើម្បីដកអត្ថបទចេញ និងសុំទោសចំពោះការរាយការណ៍ព័ត៌មានជាភាសាខ្មែរ កាលពីថ្ងៃទី ៩ ខែកុម្ភៈ ដែលសរសេរថា កូនប្រុសរបស់លោក គឺលោក ហ៊ុន ម៉ាណែត បានចុះហត្ថលេខាលើការផ្ដល់ជំនួយទៅប្រទេសតួកគី។ ទោះបីជាវិទ្យុនេះបានចេញទាំងការសុំទោស ទាំងការដកអត្ថបទចេញក៏ដោយ ក៏អាជ្ញាធរបានដកអាជ្ញាបណ្ណរបស់វិទ្យុនេះនៅថ្ងៃទី១៣ ខែកុម្ភៈដែរ។*

*ថ្លែងទៅកាន់អ្នកចូលរួមក្នុងពិធីមួយកាលពីថ្ងៃអង្គារ អ្នកនាំពាក្យក្រសួងព័ត៌មាន លោក មាស សោភ័ណ្ឌ បាននិយាយថា ការបិទ VOD មិនមែនជាការធ្វើឱ្យបញ្ហាំងនូវបញ្ហាទូទៅទាក់ទងនឹងសេរីភាពសារព័ត៌មាននោះទេ។*

*លោកនិយាយថា៖ «ខ្ញុំសូមបញ្ជាក់ថា ការបិទ VOD មិនសម្លាប់សេរីភាពសារព័ត៌មាននៅកម្ពុជាទេ» ដោយលោកអះអាងថាក្នុងករណី VOD រដ្ឋាភិបាលបានអនុវត្តទៅតាមច្បាប់ប៉ុណ្ណោះ។*

*ប៉ុន្តែក្រុមអ្នកតស៊ូមតិទទួចថា អាជ្ញាបណ្ណរបស់ VOD មិនគួរត្រូវបានដកហូតទេ ហើយថាការបិទនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់អង្គភាពសារព័ត៌មានផ្សេងទៀតនៅកម្ពុជា។*

*លោកស្រី ធន សុគន្ធា នាយកប្រតិបត្តិស្ដីទីនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបានសួរថា ក្រោយបញ្ជាឲ្យបិទ VOD តើមានប្រព័ន្ធផ្សព្វផ្សាយប៉ុន្មានហ៊ានរាយការណ៍ព័ត៌មានអំពីបាតុកម្ម និងកូដកម្ម? ។*

*លោកស្រីបានបន្ថែមថា ចាប់តាំងពីការបិទវិទ្យុនេះ មានអង្គភាពប្រព័ន្ធផ្សព្វផ្សាយតិចតួចដែលរាយការណ៍ព័ត៌មានអំពី "បញ្ហារសើបៗ" ដូចជាជម្លោះដីធ្លី ការរំលោភយកធនធានធម្មជាតិ និងការតវ៉ារបស់កម្មករជាដើម។*

*លោកស្រី សុគន្ធា បាននិយាយថា "ដូចដែលយើងដឹងស្រាប់ហើយថា ឲ្យតែជិតដល់បោះឆ្នោត អង្គភាពប្រព័ន្ធផ្សព្វផ្សាយឯករាជ្យតែងតែទទួលរងការរឹតបន្តឹង ឬបិទ"។*

*ប្រភព៖* https://tinyurl.com/mrmxweuc

# ៣. ការព្រួយបារម្ភត្រូវបានលើកឡើងទាក់ទងនឹងការរឹតត្បិតសេរីភាពអនឡាញ

*អ្នកការពារសិទ្ធិអនឡាញទូទាំងពិភពលោកព្រួយបារម្ភអំពីរដ្ឋាភិបាលនានានៅក្នុងតំបន់ ដែលកាន់តែប្រើច្បាប់ ដែលធ្វើឲ្យពួកគេមានសិទ្ធិអំណាចលើសលុបក្នុងការពិនិត្យចាប់កំហុសនូវមាតិកាអនឡាញ និងពាក់ព័ន្ធមាតិការបស់បុគ្គល ឬគេហទំព័រទាំងមូលដោយផ្អែកលើការបកស្រាយហេតុផលតាមតែអំពើចិត្ត។*

*លោក ម៉ៃឃើល ខាស្ទើរ (Michael Caster) អ្នកគ្រប់គ្រងកម្មវិធីអាស៊ីឌីជីថលរបស់មាត្រា១៩ បាននិយាយថា “ យើងឃើញមានការប៉ុនប៉ងបែបនេះនៅក្នុងប្រទេសជាច្រើននៅក្នុងតំបន់។ ខ្ញុំគិតថារឿងនេះនៅតែកើតឡើងព្រោះមាននិន្នាការកាន់តែកើនឡើងរបស់រដ្ឋាភិបាលជុំវិញពិភពលោកដែលព្យាយាមជ្រៀតជ្រែកអ៊ីនធឺណិត។ ការជ្រៀតជ្រែកបែបនេះអាចកើតមានច្រើនទម្រង់។*

*លោក ខាស្ទើរ បាននិយាយនៅក្នុងវេទិកាអ៊ិនធឺណិតភ្នំពេញកាលពីថ្ងៃព្រហស្បតិ៍ ហើយបានលើកឡើងពីការព្រួយបារម្ភអំពីការចាប់ពិរុទ្ធ និងការបំបិទព័ត៌មានដែលត្រូវគេចាត់ទុកថាជាការជំទាស់ ឬបង្កគ្រោះថ្នាក់។ ការណ៍នេះអាចត្រូវធ្វើឡើងដោយការបិទវេបសាយ ត្រួតពិនិត្យមាតិកា ឬការចាប់ខ្លួន និងចាប់មនុស្សដាក់ពន្ធនាគារដោយសារតែការបញ្ចេញមតិតាមអនឡាញរបស់ពួកគេ។*

*លោក ខាស្ទើរ បានកត់សម្គាល់ថា មានរឿងមួយចំនួនដែលអាចធ្វើបាន ដើម្បីដោះស្រាយនិន្នាការទាំងនេះ។ រដ្ឋាភិបាលគួរតែលុបចោលច្បាប់ដែលរឹតត្បិតសេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិទទួលបានព័ត៌មាន។ ពួកគេក៏គួរតែធានាថា កងកម្លាំងសន្តិសុខរបស់ពួកគេមិនជ្រៀតជ្រែកអ៊ីនធឺណិត។*

*លោក ខាស្ទើរ បានបន្តថា“ការណ៍នេះកំពុងដោះស្រាយកង្វល់សមហេតុផល ការរីករាលដាលនៃព័ត៌មានមិនពិតដែលបង្កគ្រោះថ្នាក់ ឬអាចបង្កគ្រោះថ្នាក់ ឬការបំភ្លៃព័ត៌មាន។ យ៉ាងណាក៏ដោយ ការឆ្លើយតបចំពោះការព្រួយបារម្ភនេះផ្ទុយពីគោលការណ៍សិទ្ធិមនុស្សទៅវិញ។ យើងត្រូវការដំណោះស្រាយដែលផ្អែកលើសិទ្ធិមនុស្ស ដើម្បីដោះស្រាយបញ្ហានិងកង្វល់ទាំងនេះប្រកបដោយប្រសិទ្ធភាព»។*

*នៅក្នុងប្រទេសថៃ ច្បាប់ស្តីពីឧក្រិដ្ឋកម្មទាក់ទងនឹងកុំព្យូទ័រ (CRCA) ត្រូវបានប្រើប្រាស់ ដើម្បីកំណត់គោលដៅលើបុគ្គលដែលបានបញ្ចេញមតិរិះគន់ ឬការជំទាស់តាមអនឡាញ។ ឧទាហរណ៍ ប្រជាជនត្រូវបានតុលាការកាត់ទោសឱ្យជាប់ពន្ធនាគារច្រើនឆ្នាំពីបទប្រើសញ្ញា hashtag នៅលើហ្វេសប៊ុក ដែលរិះគន់របបរាជានិយម។*

*នៅប្រទេសវៀតណាម ក្រមព្រហ្មទណ្ឌត្រូវបានប្រើប្រាស់ ដើម្បីកំណត់គោលដៅលើបុគ្គលដែលបានចែករំលែក ឬផ្សព្វផ្សាយព័ត៌មានដែលរិះគន់រដ្ឋាភិបាល ឬបក្សកុម្មុយនិស្ត។*

*លោក ខាស្ទើរ បាននិយាយថា ប្រទេសវៀតណាម គឺជាឧទាហរណ៍នៃកាបំភ្លៃក្រមព្រហ្មទណ្ឌ ដើម្បីបំបិទសេរីភាពនៃការបញ្ចេញមតិ។ នៅក្រោមមាត្រាតែមួយនៃក្រម បុគ្គលត្រូវប្រឈមមុខនឹងការកាត់ទោសធ្ងន់ធ្ងររហូតដល់២០ ឆ្នាំពីបទចែករំលែក ឬផ្សព្វផ្សាយ "ការឃោសនាប្រឆាំងនឹងរដ្ឋ" ។*

លើសពីនេះ ប្រជាជនត្រូវបានតុលាការកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេលពី៨ឆ្នាំទៅ ១៦ ឆ្នាំ ពីបទបញ្ចេញមតិតាមអនឡាញ ជាពិសេសនៅលើថ្នាលវេទិកាដូចជាហ្វេសប៊ុក ជាដើម។

បន្ថែមពីលើការចាប់ពិរុទ្ធនោះ រដ្ឋាភិបាលក៏កំពុងដាក់កម្រិតលើសិទ្ធិឯកជនភាព ដោយតម្រូវឱ្យមានការផ្ទៀងផ្ទាត់ឈ្មោះត្រឹមត្រូវសម្រាប់គណនីប្រព័ន្ធផ្សព្វផ្សាយសង្គម និងស៊ីមកាត។ កិច្ចខិតខំប្រឹងប្រែងទាំងនេះច្រើនតែត្រូវបានបញ្ជាក់ថាត្រឹមត្រូវ ដោយការអះអាងថាពួកគេចាំបាច់ដើម្បីទប់ស្កាត់សកម្មភាពឧក្រិដ្ឋកម្ម។ លោកបានបន្ថែមថា ទោះជាយ៉ាងណាក៏ដោយ ការផ្ទៀងផ្ទាត់ឈ្មោះពិតបានរំលោភលើភាពអាចចូលរួមដោយអនាមិកតាមអនឡាញ ដែលមានសារៈសំខាន់សម្រាប់ការពារសិទ្ធិសេរីភាពនៃការបញ្ចេញមតិ។

លោកបាននិយាយថា អ្នករាយការណ៍ពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស បានបញ្ជាក់ថា ភាពអាចបញ្ចេញមតិដោយអនាមិកតាមអ៊ីនធឺណិត ផ្តល់នូវការការពារមួយកម្រិត ដែលលើកទឹកចិត្ត និងការពារការអនុវត្តសិទ្ធិសេរីភាពនៃការបញ្ចេញមតិ។ វាមានសារៈសំខាន់ណាស់នៅក្នុងសង្គមដែលអ្នកសារព័ត៌មាន មេធាវី និងអ្នកការពារសិទ្ធិមនុស្សផ្សេងទៀតអាចប្រឈមនឹងហានិភ័យនៃការសងសឹកចំពោះការងាររបស់ពួកគេ។

លោកខាស្មើរបាននិយាយថា"យើងក៏ត្រូវចងចាំគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្សផងដែរ។ ខណៈពេលដែលគោលការណ៍ទាំងនេះមិនមែនជាច្បាប់រឹងមាំនោះ វាគឺជាបណ្តុំនៃការអនុវត្តល្អបំផុតដែលបង្ហាញពីការទទួលខុសត្រូវសាជីវកម្មនៃវិស័យឯកជនជាពិសេសក្រុមហ៊ុនបច្ចេកវិទ្យា ដើម្បីការពារសិទ្ធិមនុស្ស"។

លោក ណុប វី នាយកប្រតិបត្តិនៃសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA) បាននិយាយក្នុងវេទិកាថា ច្បាប់មួយចំនួនដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននេះ ត្រូវតែគាំទ្រយ៉ាងពេញទំហឹងទៅលើសេរីភាពអ៊ីនធឺណិត។

លោកនិយាយថា"ប្រសិនបើយើងពិនិត្យឲ្យកាន់តែដិតដល់ កម្ពុជាមិនមានច្បាប់ដែលការពារពេញលេញគាំទ្រ និងផ្តល់សិទ្ធិទទួលបានការប្រើប្រាស់អ៊ីនធឺណិតសម្រាប់អ្នកប្រើប្រាស់ ដើម្បីឲ្យពួកគេអាចប្រើប្រាស់សិទ្ធិឌីជីថលរបស់ពួកគេបានពេញលេញនោះទេ។"

ប្រភព៖ https://tinyurl.com/4rwkvzrf

# ៤. ចាងហ្វាងកាសែតជាយដែន ត្រូវបានដោះលែងឱ្យនៅក្រៅឃុំ បន្ទាប់ពីត្រូវជាប់ឃុំបណ្ដោះអាសន្នរយៈពេលបីខែ

*លោក អ៊ុង ថាប់រ៉ាំង ចាងហ្វាងកាសែតជាយដែន ត្រូវបានដោះលែងពីពន្ធនាគារនៅថ្ងៃទី១០ ខែឧសភា បន្ទាប់ពីត្រូវចាប់ខ្លួននៅថ្ងៃទី១២ ខែកុម្ភៈ ហើយបញ្ជូនទៅពន្ធនាគារពីរថ្ងៃក្រោយមកនៅខេត្តបន្ទាយមានជ័យ។ លោកត្រូវបានចោទប្រកាន់ពីរករណី គឺបទញុះញង់ និងក្លែងបន្លំឯកសារ។*

*កូនប្រុសលោក អ៊ុង ថាប់រ៉ាំង និងមន្ត្រីអង្គការលីកាដូប្រចាំខេត្ត បញ្ជាក់ពីការដោះលែងចាងហ្វាងរូបនេះ។ ទោះជាយ៉ាងណា លោកចាងហ្វាងនៅតែស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ។*

*លោក ធន់ ឈិន អ្នកសម្របសម្រួលនៃអង្គការសិទ្ធិមនុស្សលីកាដូប្រចាំខេត្ត បានប្រាប់ខេមបូចា ថា លោក ថាប់រ៉ាំងបានចុះផ្សាយព័ត៌មានជាបន្តបន្ទាប់អំពីអំពើពុករលួយនៅក្នុងមន្ទីរសុខាភិបាលខេត្តនិងការិយាល័យពន្ធដារ។ លោក ថាប់រ៉ាំង ត្រូវបានមន្ត្រីមកពីមន្ទីរនិងការិយាល័យនេះប្ដឹងពីបទញុះញង់ និងបរិហារកេរ្តិ៍។*

*លោកក៏ត្រូវបានចោទប្រកាន់ពីបទក្លែងបន្លំឯកសារ ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិនៅក្រុងប៉ោយប៉ែតដែរ។*

*ប្រភព៖ ខេមបូចា បានសម្ភាសកូនប្រុសលោក ថាប់រ៉ាំង និងមន្ត្រីអង្គការលីកាដូ*

# ៥. សន្ទស្សន៍សេរីភាពសារព័ត៌មានឆ្នាំ២០២៣ របស់កម្ពុជាបន្តធ្លាក់ចុះ

*យោងតាមរបាយការណ៍របស់អង្គការអ្នកកាសែតគ្មានព្រំដែនដែលចេញផ្សាយក្នុងទិវាសេរីភាពសារព័ត៌មានពិភពលោក កាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ ចំណាត់ថ្នាក់សេរីភាពសារព័ត៌មានរបស់កម្ពុជានៅឆ្នាំ២០២៣ បានធ្លាក់ចុះ ខណៈដែលរដ្ឋាភិបាលបន្តធ្វើទុក្ខបុកម្នេញមកលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។*

*កម្ពុជាជាប់ចំណាត់ថ្នាក់លេខ ១៤៧ ក្នុងចំណោមប្រទេសចំនួន ១៨០ ពោលគឺធ្លាក់ចុះពីចំណាត់ថ្នាក់លេខ ១៤២ ក្នុងឆ្នាំ ២០២២។*

*ពិន្ទុសរុបរបស់ប្រទេសកម្ពុជាបានធ្លាក់ចុះមួយពិន្ទុពី៤៣ ក្នុងឆ្នាំ ២០២២ មកនៅត្រឹម៤២ ក្នុងឆ្នាំ ២០២៣។ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក អង្គការអ្នកកាសែតគ្មានព្រំដែនបានកត់សម្គាល់ថា កម្ពុជាមានចំណាត់ថ្នាក់ខ្ពស់ជាងប្រទេសវៀតណាម មីយ៉ាន់ម៉ា និងឡាវ។*

របាយការណ៍បាននិយាយពីកម្ពុជាថា៖ «ការផ្លាស់ប្តូរតាមបែបប្រជាធិបតេយ្យដែលបានចាប់ផ្តើមនៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ បានធ្វើឲ្យមានសារព័ត៌មានរីកដុះដាលរហូតមកដល់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលកាន់អំណាចយូរមកហើយ គឺបានបង្កើតសង្គ្រាមប្រឆាំងនឹងសារព័ត៌មានឯករាជ្យនៅមុនការបោះឆ្នោតឆ្នាំ ២០១៨»។

អង្គការអ្នកកាសែតគ្មានព្រំដែន បាននិយាយថា "ស្ថានីយវិទ្យុ និងកាសែតត្រូវបំបិទមាត់ បន្ទប់ព័ត៌មានត្រូវបានកម្ចាត់ចោល អ្នកកាសែតត្រូវបានផ្តន្ទាទោស ដែលធ្វើឱ្យវិស័យសារព័ត៌មានឯករាជ្យត្រូវបំផ្លាញចោល"។ អង្គការនេះបញ្ជាក់ថា លោក ហ៊ុន សែន ក៏បានប្រើយុទ្ធសាស្ត្រស្រដៀងគ្នានេះដែរ មុនការបោះឆ្នោតនៅឆ្នាំនេះ។

អង្គការអ្នកកាសែតគ្មានព្រំដែន បាននិយាយថា កាសែត ភ្នំពេញប៉ុស្តិ៍បានបាត់បង់ឯករាជ្យរបស់ខ្លួន បន្ទាប់ពីកាសែតនេះត្រូវឧកញ៉ាដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយលោកនាយករដ្ឋមន្ត្រីបានទិញនៅឆ្នាំ២០១៨។ ប៉ុន្មានខែក្រោយមក ស្ថានីយវិទ្យុឯករាជ្យជាង៣០ ត្រូវបានបង្ខិតបង្ខំឱ្យបិទ។ ក្នុងចំណោមអង្គភាពសារព័ត៌មានទាំងនេះ មានវិទ្យុសំឡេងប្រជាធិបតេយ្យ ដែលមានកម្មវិធីចាក់ផ្សាយឡើងវិញដោយស្ថានីយក្នុងស្រុកដោយហេតុដូច្នេះហើយ ទើបវិទ្យុនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មានឯករាជ្យ ជាពិសេសនៅតាមតំបន់ជនបទជាដើម។

ប្រភព៖ https://rsf.org/en/country/cambodia

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា

*Cambodian Journalists Alliance Association*

# ទំនាក់ទំនង


+855 (0)23 88 23 11

communications@camboja.net

ផ្ទះលេខ១៩ ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃ១
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ